ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ៥៧១
ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ ៥៦២
ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២
**សាលក្រមព្រហ្មទណ្ឌ**
**លេខ: ៧៨ "ច"/៧៣៧**
ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២

## សាលក្រម

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

-បានបើកសវនាការជាសាធារណៈ នៅសាលសវនាការលេខ ក១ ។
-កាលបរិច្ឆេទបើកសវនាការ ៖ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ វេលារសៀល ។
-កាលបរិច្ឆេទប្រកាសសាលក្រម ៖ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ វេលាព្រឹក ។

**សមាសភាពចូលរួមសវនាការមាន៖**

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ឋានៈ ចៅក្រម

**តំណាងអយ្យការ**

លោកស្រី [redacted] ឋានៈ ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈ ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧១ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] ឈាង ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរអ្នកបើករថយន្ត កំរិតវប្បធម៌ថ្នាក់ទី៤ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ចាម ទីលំនៅមុនពេលចាប់ខ្លួននៅភូមិអណ្តូងតាឡឹក ឃុំថ្មពូន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ [redacted] ស្រីល័ក្ខ មានកូន ២នាក់ ឪពុកឈ្មោះ [redacted] យ៉ាន "ស្លាប់" ម្តាយឈ្មោះ [redacted] រឹន "រស់" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន ។ (ក្នុងឃុំ)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥៨ យខ/ធ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្តាលឲ្យស្លាប់អ្នកដទៃ ប្រព្រឹត្តនៅចន្លោះគីឡូម៉ែត្រលេខ ៣៣៧ និងលេខ ៣៣៨ ស្ថិតនៅភូមិដំណាក់ស្លាញ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

## ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] សុទ្ធាវី ភេទស្រី កើតឆ្នាំ១៩៦៣ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងថ្មខាងត្បូង ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ (អវត្តមាន) ។

-លោកមេធាវី [redacted]ជាមេធាវីការពារសិទ្ធិ (អវត្តមាន) ។

-លោកស្រីមេធាវី[redacted] ជាមេធាវីការពារសិទ្ធិ (អវត្តមាន) ។

## អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ឈ្មោះ [redacted] សុខអេង ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិថ្មពួនកណ្តាល ស្រុកថ្មពួន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

## អង្គហេតុកើតឡើងមានដូចតទៅ៖

កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៦:២៥នាទី ស្ថិតនៅចន្លោះគីឡូម៉ែត្រលេខ ៣៣៧ លេខ ៣៣៨ ភូមិដំណាក់ស្លាញ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានរថយន្តចំនួន ១ (មួយ) គ្រឿង ម៉ាក Mitsubishi Super Great ប្រភេទក្បាលសណ្តោង ពណ៌ទឹកប្រាក់លាយបៃតង ពាក់ផ្លាកលេខ កំពង់ចាម 3A-7770 សណ្តោងរ៉ឺម៉ក ពណ៌ខៀវ ពាក់ផ្លាកលេខ កំពង់ចាម 4A-0621 បើកបរដោយឈ្មោះ [redacted] ឈាង ក្នុងទិសដៅពីលិចទៅកើត បានបុកនឹងម៉ូតូចំនួន ១គ្រឿងម៉ាក ហុងដាឌ្រីម សេរី ឆ្នាំ២០១៨ ពណ៌ខ្មៅ ផ្លាកលេខ បន្ទាយមានជ័យ 1S-8897 បើកបរដោយឈ្មោះ [redacted] វណ្ណៈ ក្នុងទិសដៅពីលិចទៅកើតបណ្តាលឲ្យស្លាប់ ។

បានឃើញ របាយការណ៍លេខ ១៤២/២០២២ នប/ស្រព ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកពួក នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៥៣១ អយច/២២ ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៧៤២ ពស.ព្រទ/ឈ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៦៦៨ ពស.ព្រជ(ក) ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## នាពេលសវនាការ

១.ជនជាប់ចោទឈ្មោះ [redacted] ឈាន បានឆ្លើយថា កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៦:២៥នាទី ខ្លួនបានបើករថយន្ត ១(មួយ)គ្រឿង ម៉ាក Mitsubishi Super Great ប្រភេទក្បាលសណ្តោង ពណ៌ទឹកប្រាក់លាយបៃតង ពាក់ផ្លាកលេខ កំពង់ចាម 3A-7770 សណ្តោងរ៉ឺម៉ក ពណ៌ខៀវ ពាក់ផ្លាកលេខ កំពង់ចាម 4A-0621 មានទិសដៅពីលិចទៅកើតកាត់តាមភូមិដំណាក់ស្លាញ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប ពេលខ្លួនបើកបររថយន្តខាងនេះដល់ចំណុចស្រុកពួក មានសមត្ថកិច្ចឃាត់ខ្លួន ថាខ្លួនជិះរថយន្តខាងលើនេះបុកម៉ូតូបណ្តាលឲ្យអ្នកបើកម៉ូតូស្លាប់។ ប៉ុន្តែពេលនោះខ្លួនឆ្លើយថា ខ្លួនបើកបរពុំមានគ្រោះថ្នាក់ទេ ហើយសមត្ថកិច្ចបានពិនិត្យរថយន្តរបស់ខ្លួន ឃើញមានកងរថយន្តខាងក្រោយផ្នែកខាងស្តាំមានស្នាមជាប់ឈាម ។ រថយន្តដែលខ្លួនបើកបរខាងលើនេះមានប្រវែង ១២ម៉ែត្រ ដឹកសត្វគោ ។ ឃាត់ខ្លួនពី

កន្លែងកើតហេតុជាង ១៧គីឡូម៉ែត្រ ។ ខ្លួនបើកបរជាមួយប្រុយរថយន្តម្នាក់ទៀត តែប្រុយនោះក៏ឆ្លើយថា ពុំមានបុកនឹងម៉ូតូអ្វីដែរ ។ ខ្លួនមានប័ណ្ណបើកបរម៉ូតូត្រឹមត្រូវ ខ្លួនបើកបររថយន្តខាងលើនេះជាង ១២ឆ្នាំ ។ រថយន្តដែលខ្លួនបើកខាងលើនេះជារបស់ឈ្មោះ [redacted] សុខអេង ក្រោយកើតហេតុនេះខ្លួនបានសងសំណងទៅជនរងគ្រោះរួចអស់ទៅហើយៗ ជនរងគ្រោះក៏បានដកពាក្យបណ្ដឹងដែល ។ ខ្លួនពិតជាមិនដឹងថា បើករថយន្តបុកម៉ូតូមែន ព្រោះម៉ូតូបានចូលកង់រថយន្តខ្លួនខាងក្រោយ ខ្លួនដឹងកំហុស មានការស្ដាយក្រោយ ទើបបើកបរគ្រោះថ្នាក់លើកទីមួយ ។

សាក្សីឈ្មោះ [redacted]ចិត្ត បានឆ្លើយថា ថ្ងៃកើតហេតុ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ម៉ោង ៦:៣០ ខ្លួនកំពុងលើកភ្លឺស្រែលឺសម្លេងលាន់ឡើងផាំង ខ្លួនក្រឡេកទៅឃើញអ្នកជិះម៉ូតូដួល ខ្លួនរត់ទៅមើលឃើញដេកស្លាប់ ដោយខ្លួនភ័យស្លន់ស្លោពេកក៏ទូរស័ព្ទរាយការណ៍ប៉ុស្តិ៍តែម្ដង ។ រថយន្តដែលបើកបុកម៉ូតូនោះពណ៌ខៀវ ហើយសមត្ថកិច្ចបានហៅខ្លួនទៅចង្អុលរថយន្តបើកបុកម៉ូតូនោះ ហើយខ្លួនបានចង្អុលប្រាប់សមត្ថកិច្ចគេក៏បានថតរូបដែល ។ រថយន្តបើកបុកកង់ក្រោយផ្នែកខាងស្ដាំ ខ្លួននៅចម្ងាយពីរថយន្តប្រហែល ៥០ម៉ែត្រ មើលឃើញច្បាស់ ព្រោះមេឃនៅភ្លឺ ។

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានបញ្ចប់ការសួរដេញដោល និងពិនិត្យកស្តុតាងផ្សេងៗក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ឈាង ត្រូវបានញ្ជូនមកជំនុំជម្រះពីបទៈ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្ដាលឲ្យស្លាប់អ្នកដទៃ ប្រព្រឹត្តនៅចន្លោះគីឡូម៉ែត្រលេខ ៣៣៧ និងលេខ ៣៣៨ ស្ថិតនៅភូមិដំណាក់ស្លាញ ឃុំសសរស្ដម្ភ ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។ នាពេលសវនាការជនជាប់ចោទបានឆ្លើយថា ខ្លួនបើករថយន្តខាងលើនេះពុំដឹងថាមានបុកត្រូវនឹងអ្វីនោះទេ បើធៀបនឹងរថយន្តរបស់ជនជាប់ចោទមានទំហំធំ ហើយបុកនៅកង់ក្រោយគេបំផុត ដូចនេះអាចថាជនជាប់ចោទពុំដឹងមែន ។ ប៉ុន្តែតាមចម្លើយសាក្សីថា រថយន្តដែលបើកបុកម៉ូតូនោះពណ៌ខៀវ មួយទៀតជនជាប់ចោទក៏បានទទួលស្គាល់ដែលថា រថយន្តខ្លួនកង់ខាងក្រោយផ្នែកខាងស្ដាំមានប្រឡាក់ឈាម និងស្នាមក្លូតកង់ ។ ដូចនេះ តំណាងអយ្យការជឿថា ជនជាប់ចោទពិតជាបានបើករថយន្តខាងលើបុកនឹងម៉ូតូប្រាកដមែន ។ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ខាងលើ និងប្ដឹងសុំឲ្យតុលាកាផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋានការពារថា កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ជនជាប់ចោទបានបើករថយន្តចំនួន ១(មួយ)គ្រឿង ម៉ាក Mitsubishi Super Great ប្រភេទក្បាលសណ្ដោង ពណ៌ទឹកប្រាក់លាយបៃតង ពាក់ផ្លាកលេខ កំពង់ចាម 3A-7770 សណ្ដោងរ៉ឺម៉ក ពណ៌ខៀវ ពាក់ផ្លាកលេខ កំពង់ចាម 4A-0621 ជាមួយប្រុយម្នាក់ទៀត ។ ពេលជនជាប់ចោទបើកដល់កំណុចកើតហេតុពុំដឹងមានបុកនឹងអ្វីឡើយ សម្បីតែប្រុយជិះជាមួយក៏ពុំដឹងថា មានបុកនឹងអ្វីដែលបើជនជាប់ចោទដឹងថា ខ្លួនបុកនឹងម៉ូតូនោះជនជាប់ចោទប្រាកដជានឹងឈប់ដោះស្រាយជាមិនខាន ។ ក្រោយពីជនជាប់ចោទដឹងថា ខ្លួនបុកនឹងម៉ូតូមានការស្ដាយក្រោយ ហើយជនជាប់ចោទក៏បានសងសំណងទៅឲ្យជនរងគ្រោះរួចអស់ទៅហើយៗ ជនរងគ្រោះក៏បានដកពាក្យបណ្ដឹងរដ្ឋប្បវេណីថែមទៀត ។ ដូចនេះ

ស្នើសុំតុលាការជួយបន្ធូរបន្ថយទោស និងប្រកាសទោសត្រឹមកម្រិតនៃការឃុំខ្លួនបណ្ដោះអាសន្ននេះបានហើយ ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ខ្លួនឯកភាពនឹងសេចក្ដីសន្និដ្ឋានរបស់សហភាគីខាងលើទាំងអស់ ពុំមានអ្វីបន្ថែមទៀតទេ ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ**

-ជនជាប់ចោទឈ្មោះ [redacted] ឈាន បានសំណូមពរមកតុលាការថា សូមឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ក្រោយពីបាន ស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបាន ស្ដាប់ចម្លើយរបស់សាក្សី

-ក្រោយពីបាន ស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបាន ស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបាន ស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបាន ពិនិត្យលើកស្ដុតាងឯកសារផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបាន ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១.ឈ្មោះ [redacted] ឈាង ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្ដាលឲ្យស្លាប់អ្នកដទៃ ប្រព្រឹត្តនៅចន្លោះគីឡូម៉ែត្រលេខ៣៣៧ និងលេខ៣៣៨ ស្ថិតនៅភូមិដំណាក់ស្លាញ ឃុំសសរស្ដម្ភ ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។ តាមដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៧៤២ ពស.ព្រស/ឈ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប ។

២.ជនជាប់ចោទឈ្មោះ [redacted] ឈាន បានឆ្លើយគ្រប់ដំណាក់កាលនៃនីតិវិធីដូចគ្នាថា កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៦:២៥នាទី ខ្លួនបានបើករថយន្តចំនួន ១ (មួយ)គ្រឿង ម៉ាក Mitsubishi Super Great ប្រភេទក្បាលសណ្ដោង ពណ៌ទឹកប្រាក់លាយបៃតង ពាក់ផ្លាកលេខ កំពង់ចាម 3A-7770 សណ្ដោងរ៉ឺម៉ក ពណ៌ខៀវ ពាក់ផ្លាកលេខ កំពង់ចាម 4A-0621 ដឹកសត្វគោ មានទិសដៅពីលិចទៅកើតកាត់តាមភូមិដំណាក់ស្លាញ ឃុំសសរស្ដម្ភ ស្រុកពួក ខេត្តសៀមរាប ។ បន្ទាប់ពីខ្លួនបើករថយន្តដល់ស្រុកពួកមានសមត្ថកិច្ចមកឃាត់ខ្លួនថា ខ្លួនបើករថយន្តខាងលើបុកនឹងម៉ូតូចំនួន ១(មួយ)គ្រឿង បណ្ដាលឲ្យអ្នកបើកបរម៉ូតូស្លាប់ ។ ខ្លួនពុំដឹងថា ខ្លួនបានបើករថយន្តបុកនឹងម៉ូតូនោះទេ សូម្បីតែប្រួជិះរថយន្តជាមួយខ្លួនក៏ពុំដឹងដែលថា រថយន្តខ្លួនបុកត្រូវនឹងអ្វី ។ ប៉ុន្តែខ្លួនទទួលស្គាល់ថា ពេលសមត្ថកិច្ចឃាត់ខ្លួនត្រួតពិនិត្យរថយន្តខ្លួន គឺកង់រថយន្តកង់ក្រោយផ្នែកខាងស្ដាំមានស្នាមកូតនឹងប្រឡាក់ឈាម ។ ចម្លើយជនជាប់ចោទរូបនេះស្របជាមួយចម្លើយរបស់សាក្សីឆ្លើយបញ្ជាក់ប្រាកដមែន ។

៣.សាក្សីឈ្មោះ [redacted] ចិត្ត បានឆ្លើយគ្រប់ដំណាក់កាលនៃនីតិវិធីដូចគ្នាថា នៅថ្ងៃកើតហេតុ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ម៉ោង ៦:៣០ ខ្លួនកំពុងលើកក្ដីស្រែលឺសម្លេងលាន់ឡើងផាំង ខ្លួនក្រឡេកទៅឃើញអ្នកជិះម៉ូតូដួល ខ្លួនរត់ទៅមើលឃើញដេកស្លាប់ ដោយខ្លួនភ័យស្លន់ស្លោពេកក៏ទូរស័ព្ទរាយការណ៍ប៉ុស្តិ៍តែម្តង ។ រថយន្តដែលបើកបុកម៉ូតូនោះពណ៌ខៀវ ហើយសមត្ថកិច្ចបានហៅខ្លួនទៅចង្អុលរថយន្តបើកបុកម៉ូតូនោះ ហើយខ្លួនបានចង្អុលប្រាប់សមត្ថកិច្ចគេក៏បានថតរូបដែល ។ រថយន្តបើកបុកកង់ក្រោយផ្នែកខាងស្តាំ ខ្លួននៅចម្ងាយពីរថយន្តប្រហែល ៥០ម៉ែត្រ មើលឃើញច្បាស់ព្រោះមេឃនៅភ្លឺ ។ ចម្លើយសាក្សីអាចឲ្យតុលាការជឿជាក់បានថា ពិតជាមានករណីគ្រោះថ្នាក់ចរាចរណ៍បណ្ដាលឲ្យស្លាប់អ្នកដទៃពិតប្រាកដមែន ។

៤.តាមរបាយការណ៍លេខ ១៤២/២២ នប.ស្រព ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ និងកំណត់ហេតុបង្ហាញ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកពួក បានសន្និដ្ឋានថា ឈ្មោះ [redacted] ឈាន ជាអ្នកបើកបររថយន្តចំនួន ១(មួយ)គ្រឿង ម៉ាក Mitsubishi Super Great ប្រភេទក្បាលសណ្ដោង ពណ៌ទឹកប្រាក់លាយបៃតង ពាក់ផ្លាកលេខ កំពង់ចាម 3A-7770 សណ្ដោងរ៉ឺម៉ក ពណ៌ខៀវ ពាក់ផ្លាកលេខ កំពង់ចាម 4A-0621 មានកំហុសនៅក្នុងមាត្រា ៨៥ ចំណុច ឃ ជំពូក ១០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

៥.តាមកំណត់ហេតុប្រគល់សាកសព ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកពួក បានប្រគល់សពឈ្មោះ [redacted] វណ្ណៈទៅឲ្យឈ្មោះ [redacted] ជំនោ ត្រូវជាកូនប្រសារ ។

៦.តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកពួក បានដកហូតរថយន្តចំនួន ១(មួយ)គ្រឿង ម៉ាក Mitsubishi Super Great ប្រភេទក្បាលសណ្ដោង ពណ៌ទឹកប្រាក់លាយបៃតង ពាក់ផ្លាកលេខ កំពង់ចាម 3A-7770 សណ្ដោងរ៉ឺម៉ក ពណ៌ខៀវ ពាក់ផ្លាកលេខ កំពង់ចាម 4A-0621 ពីឈ្មោះ [redacted] ឈាន ។

៧.ផ្អែកតាមចម្លើយជនជាប់ចោទ ចម្លើយសាក្សី និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ខាងលើអាចឲ្យតុលាការសន្និដ្ឋានបានថា កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៦:២៥នាទី ឈ្មោះ [redacted] ឈាន បានបើករថយន្តចំនួន ១(មួយ)គ្រឿង ម៉ាក Mitsubishi Super Great ប្រភេទក្បាលសណ្ដោង ពណ៌ទឹកប្រាក់លាយបៃតង ពាក់ផ្លាកលេខ កំពង់ចាម 3A-7770 សណ្ដោងរ៉ឺម៉ក ពណ៌ខៀវ ពាក់ផ្លាកលេខ កំពង់ចាម 4A-0621 ក្នុងទិសដៅពីលិចទៅកើត បានបុកនឹងម៉ូតូចំនួន ១គ្រឿងម៉ាក ហុងដាឌ្រីម ស៊េរី ឆ្នាំ២០១៨ ពណ៌ខ្មៅ ផ្លាកលេខ បន្ទាយមានជ័យ 1S-8897 បើកបរដោយឈ្មោះ [redacted] វណ្ណៈ ត្រង់ចំណុចចន្លោះគីឡូម៉ែត្រលេខ ៣៣៧ លេខ ៣៣៨ ភូមិដំណាក់ស្លាញ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប បណ្ដាលឲ្យស្លាប់ ប្រាកដមែន ។

៨.ជនជាប់ចោទឈ្មោះ [redacted] ឈាន ជានីតិជន ជាមនុស្សមានស្មារតីល្អ និងមានការយល់ដឹងច្បាស់លាស់តែជនជាប់ចោទនៅតែបើកបររថយន្ត ដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្ដាលឲ្យស្លាប់អ្នកដទៃ បណ្ដាលឲ្យមានមនុស្សស្លាប់ ដែលអំពើនេះប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងអាយុជីវិតរបស់មនុស្ស ពិសេសខុសនឹងច្បាប់រដ្ឋជាធរមាន ។

៩.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឈាន ដែលបានបើកបរថយន្តបុកជន់រងគ្រោះ ដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្ដាលឲ្យស្លាប់អ្នកដទៃ ដែលអំពើនេះកំណត់បានជាបទល្មើស បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្ដាលឱ្យស្លាប់អ្នកដទៃ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

១០.មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ឈាន ពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្ដាលឲ្យស្លាប់អ្នកដទៃ ប្រព្រឹត្តនៅចន្លោះគីឡូម៉ែត្រលេខ ៣៣៧ និងលេខ ៣៣៨ ស្ថិតនៅភូមិដំណាក់ស្លាញ ឃុំសសរស្ដម្ភ ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ នៃ ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

១១.ឈ្មោះ [redacted] សុខអេង ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ បានស្នើសុំយានយន្តចំនួន ១ (មួយ) គ្រឿង ម៉ាក Mitsubishi Super Great ប្រភេទក្បាលសណ្ដោង ពណ៌ទឹកប្រាក់លាយបៃតង ពាក់ផ្លាកលេខ កំពង់ចាម 3A-7770 សណ្ដោងរ៉ឺម៉ក ពណ៌ខៀវ ពាក់ផ្លាកលេខ កំពង់ចាម 4A-0621 ។ ផ្អែកតាមបណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩ បណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៩ លតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូន ឆ្នាំ២០២០ ឃើញថា ឈ្មោះ [redacted] សុខអេង គឺជាម្ចាស់កម្មសិទ្ធិនៃយានយន្តខាងលើ ហើយយានយន្តខាងលើនេះ មិនមែនជាវត្ថុដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើស ។ម្យ៉ាងវិញទៀត ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុទ្ធាវី ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី បានដកពាក្យបណ្ដឹង ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ ឈប់ប្ដឹងទាមទារសំណងរដ្ឋប្បវេណី លើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧១ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ។ ហេតុដូចនេះ គប្បីតុលាការសម្រេចប្រគល់វត្ថុចាប់យកខាងលើឲ្យទៅឈ្មោះ [redacted] សុអេង ស្របតាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**១២.ការប្រកាអំពីទោសៈ**

-ជនជាប់ចោទឈ្មោះ [redacted] ឈាន ប្រព្រឹត្តបទល្មើសបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច ដែលបទប្បញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្ដាលឱ្យស្លាប់អ្នកដទៃ ជាបទល្មើសមជ្ឈិម ។

-ជនជាប់ចោទឈ្មោះ [redacted] ឈាន មិនទាន់មានការផ្ដន្ទាទោសជាស្ថាពរឲ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំ មុនអំពើល្មើស ។

-ជនជាប់ចោទឈ្មោះ [redacted] ឈាន បានឆ្លើយសារភាពគ្រប់ដំណាក់កាលនៃនីតិវិធី មានស្មារតីភ្ញាក់រលឹកមានការស្ដាយក្រោយចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។ មួយវិញទៀត ជនជាប់ចោទបានសងសំណងរដ្ឋប្បវេណីទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរួចអស់ហើយៗ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានដកពាក្យបណ្ដឹង ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ ឈប់ប្ដឹងទាមទារសំណងពីជនជាប់ចោទទៀតហើយ ។

-ផ្អែកតាមចំណុចទាំងនេះ គប្បីតុលាការពិចារណាប្រកាសទោសលើជនជាប់ចោទក្រោមកម្រិតជូនស្នើម និងគប្បីពិចារណាប្រកាសទោសព្យួរធម្មតាមួយផ្នែកឲ្យជនជាប់ចោទ ស្របតាមមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ សម្រេច

**១.ផ្តន្ទាទោស ៖** ឈ្មោះ [redacted] ឈាង ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ (ដែលមានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១(មួយ)ឆ្នាំ ប៉ុន្តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ៦(ប្រាំ)ខែ ទោសសល់ពីនេះត្រូវព្យួរធម្មតា ។

ពីបទៈ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្តាលឲ្យស្លាប់អ្នកដទៃ ប្រព្រឹត្តនៅចន្លោះគីឡូម៉ែត្រលេខ ៣៣៧ និងលេខ ៣៣៨ ស្ថិតនៅភូមិដំណាក់ស្លាញ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ នៃ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

**២.**វត្ថុចាប់យកមាន រថយន្តចំនួន ១ (មួយ)គ្រឿង ម៉ាក Mitsubishi Super Great ប្រភេទក្បាលសណ្តោង ពណ៌ទឹកប្រាក់លាយបៃតង ពាក់ផ្លាកលេខ កំពង់ចាម 3A-7770 សណ្តោងរ៉ឺម៉ក ពណ៌ខៀវ ពាក់ផ្លាកលេខ កំពង់ចាម 4A-0621 ប្រគល់ទៅឲ្យឈ្មោះ [redacted] សុខអេង ភេទប្រុស ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានភូមិថ្មពូនកណ្តាល ឃុំថ្មពូន ស្រុកព្រៃឈរ ខេត្តកំពង់ចាម តាមបញ្ញត្តិមាត្រា ៣៥៤ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ឈាន និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុទ្ធាវី ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១០រោច ខែអស្សុជ ឆ្នាំខ្លាល ត្រីស័ក ព.ស ២៥៦៦
សៀមរាប ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប ថ្ងៃទី៣ ខែ[illegible] ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]